មាត្រា ២ ._

ភ្នាក់ងារសុខភាពសត្វភូមិនេះ មិនត្រូវជាភ្នាក់ងាររដ្ឋទេ គឺជាភ្នាក់ងារដែលត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ឬ សិស្ស-និស្សិតដែលបានទទួលការបណ្តុះបណ្តាល មកទទួលការបណ្តុះបណ្តាល និងបំពាក់បំប៉នបច្ចេកទេសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ៣ ._

នីតិវិធីនៃការជ្រើសរើស ការបណ្តុះបណ្តាល ការទ្រទ្រង់សកម្មភាព ការគ្រប់គ្រងអោយមាននិរន្តរភាព តួនាទី និងភារកិច្ចរបស់ភ្នាក់ងារសុខភាពសត្វភូមិ និងគោលការណ៍ពាក់ព័ន្ធដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ៤ ._

បទប្បញ្ញត្តិដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ២៧ អនក្រ.បក

## ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តព្រៃវែង ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

---

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យ ជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**មាត្រា ១ .-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តព្រៃវែង ដូចតទៅ :

-លុបចេញនាទីឡូត៍នេសាទលេខ ៧. ៨.១២.៩.១៦ និងលេខ ១៧ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។

-កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តព្រៃវែង និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តព្រៃវែង ដែលត្រូវលុប និងកាត់បន្ថយ

ឯកតា ( ហិកតា )

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសេស | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១ | ១១.៣៦៨ | ៥.០៥៩ | ៦.៣០៩ | ៤៤.៥០ | |
| ២ | ១៧.៥២៦ | ៧.២៥១ | ១០.២៧៥ | ៤១.៣៧ | |
| ៣ | ៥.២០១ | ៣.៨៥៣ | ១.៣៤៨ | ៧៤.០៨ | |
| ៤ | ៦.២៣៣ | ២.៥៤២ | ៣.៦៩១ | ៤០.៧៨ | |
| ៥ | ៥.២៧៩ | ៣.២២២ | ២.០៥៧ | ៦១.០៣ | |
| ៦ | ១៤.៣១៨ | ១១.៨០០ | ២.៥១៨ | ៨២.៤១ | |
| ៧ | ២.៦២៣ | ២.៦២៣ | 0 | ១០០ | លុបចេញ |
| ៨-១២ | ៨.៥១៨ | ៨.៥១៨ | 0 | ១០០ | លុបចេញ |
| ៩ | ១៤.២៦៩ | ១៤.២៦៩ | 0 | ១០០ | លុបចេញ |
| ១០ | ២០.២៧៨ | ១២.៧៧០ | ៧.៥០៨ | ៦២.៩៧ | |
| ១១ | ២.៩៦៥ | ២.២៩៦ | ៦៦៩ | ៧៧.៤៣ | |
| ១៣ | ៥.៤៣១ | ១.៩២៦ | ៣.៥០៥ | ៣៥.៤៦ | |
| ១៤ | ២.៧២៣ | ១.១១១ | ១.៦០២ | ៤០.៩៥ | |
| ១៥ | ៣.៥២៦ | ៦១២ | ២.៩១៤ | ១៧.៣៥ | |
| ១៦ | ៤.៥១៨ | ៤.៥១៨ | 0 | ១០០ | លុបចេញ |
| ១៧ | ៣.១៣៣ | ៣.១៣៣ | 0 | ១០០ | លុបចេញ |
| ១៨ | ៤.៩៧៤ | ៦៥៨ | ៤.៣១៦ | ១៣.២២ | |
| ១៩ | ២.៧៣៥ | ១.១៥៩ | ១.៥៧៦ | ៤២.៣៧ | |
| ២០ | ៧.៤៦១ | ៤០៩ | ៧.០៥២ | ៥.៤៨ | |
| សរុប ១៩ | ១៤៣.០៦៩ | ៨៧.៧២៩ | ៥៥.៣៤០ | ៦១.៣១ | |

**មាត្រា ២ .-**

ដែននេសាទដែលបានលុបចេញ និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុងហែងយកទៅលក់ ឬជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមណ៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តតាមអនុក្រឹត្យនេះតាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ៩២ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី